**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៣-០០១ ស.រ.ជ.ក

រាជធានីភ្នំពេញ ថ្ងៃទី២០ខែកញ្ញា ឆ្នាំ២០១៣

# សារាចរណែនាំ

# ស្តីពី

# ការអនុវត្តប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានធនាគារជាតិនៃកម្ពុជា ដាក់ឲ្យប្រើប្រាស់កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ។ ដើម្បីឲ្យការអនុវត្តប្រកាសនេះមានដំណើរការប្រកប ដោយប្រសិទ្ធភាពនិងសម្រេចបានគោលដៅ ធនាគារជាតិនៃកម្ពុជាសូមធ្វើការណែនាំអំពីការអនុវត្តខ្លឹមសារនៃ ប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចខាងក្រោម៖

**១- ធនាគារពាណិជ្ជ សាខាធនាគារបរទេស និង ធនាគារឯកទេស**

**- ទីស្នាក់ការកណ្តាល សាខារង សាខារាជធានី សាខាខេត្ត ដែលមានអាជ្ញាបណ្ណ**

ទីស្នាក់ការកណ្តាល សាខារង សាខារាជធានី សាខាខេត្ត ដែលមានអាជ្ញាបណ្ណរួចហើយ ត្រូវបង់សោហ៊ុយ អាជ្ញាបណ្ណប្រចាំឆ្នាំស្របតាមប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចាប់ពីខែ មករា ឆ្នាំ២០១៤ តទៅ ។

**- សាខាក្រុង សាខាស្រុក និងប៉ុស្តិ៍សេវា ដែលមានលិខិតអនុញ្ញាត**

សាខាក្រុង សាខាស្រុក ត្រូវដាក់ពាក្យសុំអាជ្ញាបណ្ណចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ។ សាខាក្រុង សាខាស្រុក និងប៉ុស្តិ៍សេវា ត្រូវបង់សោហ៊ុយអាជ្ញាបណ្ណ ឬសោហ៊ុយលិខិត អនុញ្ញាតប្រចាំឆ្នាំស្របតាមប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចាប់ពីខែ មករា ឆ្នាំ២០១៤ តទៅ ។

**- ទីស្នាក់ការកណ្តាល សាខារង សាខារាជធានី សាខាខេត្ត ដែលនឹងបង្កើតថ្មី**

គ្រឹះស្ថានធនាគារ ដែលមានបំណងបើកទីស្នាក់ការកណ្តាល សាខារង សាខារាជធានី សាខាខេត្ត ត្រូវដាក់ពាក្យសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា និងត្រូវបង់សោហ៊ុយស្របតាមប្រកាសស្តីពីការកំណត់សោហ៊ុយ សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

– **សាខាក្រុង សាខាស្រុក និងប៉ុស្តិ៍សេវា ដែលនឹងបង្កើតថ្មី**

គ្រឹះស្ថានធនាគារ ដែលមានបំណងបើកសាខាក្រុង សាខាស្រុក និងប៉ុស្តិ៍សេវា ត្រូវដាក់ពាក្យសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា និងត្រូវបង់សោហ៊ុយស្របតាមប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**២- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបើកដំណើរការអាជីវកម្មជាសាខារាជធានី សាខាខេត្ត សាខាក្រុង និងសាខាស្រុក ឬប៉ុស្តិ៍សេវា ដោយពុំទាន់មានអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ និងត្រូវបង់សោហ៊ុយស្របតាមប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**៣- គ្រឹះស្ថានផ្សេងទៀត**

គ្រឹះស្ថានផ្សេងទៀត ត្រូវអនុវត្តការបង់សោហ៊ុយផ្សេងៗស្របតាមប្រកាសស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

សារាចរណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសាភិបាល**

**ជា.ចាន់តូ**